**អង្គរបុរី**
**សម្លេងខ្មែរនៅបរទេស**

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ពុទ្ធភាសិតថា ធម៌ហ្នឹងឯងតែងរក្សាអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំល្អហើយ តែងនាំមកនូវសេចក្តីសុខ ។

website: www.hoksavann.org
ថ្ងៃទី២ កញ្ញា ២០០៧



ពុទ្ធភាសិតនេះចេញមកពីបាលី ធម្មោ ហវេ រក្ខតិ ធម្មចារី ធម្មោ សុចិណ្ណោ សុខមាហាតិ ប្រែថា ធម៌ហ្នឹងឯងតែងរក្សាអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំល្អហើយ តែងនាំនូវសេចក្តីសុខ ។ ពាក្យថាធម៌ក្នុងព្រះពុទ្ធសាសនានេះ សំដៅយកកុសលធម៌ គឺអំពើល្អដែលប្រព្រឹត្តទៅតាមកាយវាចានិងចិត្ត ។ ការប្រព្រឹត្តល្អតាមផ្លូវកាយមានបីគឺ ការមិនសម្លាប់មនុស្សសត្វ, មិនលួចទ្រព្យសម្បត្តិអ្នកដទៃ, ការមិនរំលោភលើប្រពន្ធកូននិងប្តីជនដទៃតាមផ្លូវភេទ ។ ការនិយាយល្អតាមផ្លូវវាចាមានបួនគឺ ការមិននិយាយកុហក, មិនពោលពាក្យញុះញង់បំបែកបំបាក់, មិនពោលពាក្យតិះដៀលជេរប្រទេច, មិនពោលពាក្យឥតប្រយោជន៍ ។ គំនិតល្អតាមផ្លូវចិត្តមានបីគឺ មិនមានគំនិតព្យាបាទ, មិនមានគំនិតចង់បានទ្រព្យសម្បត្តិអ្នកដទៃ, មានគំនិតយល់ត្រូវតាមសភាពពិត ។ ការប្រព្រឹត្តល្អដោយកាយវាចានិងចិត្តនេះហៅថា កុសលកម្មបថ១០។ អ្នករស់នៅតាមធម៌ជាប្រក្រតី គឺអ្នកដែលប្រព្រឹត្តធ្វើអំពើគ្រប់យ៉ាង មិនឲ្យប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃ ជាអ្នករស់នៅក្នុងសេចក្តីសុខស្ងប់ ហើយតែងមានចិត្តចង់ជួយដោះទុក្ខអ្នកដទៃផង ។ អ្នករស់នៅក្នុងធម៌ តែងមានចិត្តពុំលំអៀង ដោយស្រឡាញ់ ដោយស្អប់ ដោយភ័យខ្លាច និងដោយល្ងង់ឡើយ ។ អ្នកមានចិត្តធម៌តែងធ្វើឲ្យអ្នករស់នៅជាមួយនិងអ្នកដែលមកប្រាស្រ័យទាក់ទង បានទទួលសេចក្តីសុខ ។ អ្នកមានចិត្តធម៌តែងទទួលការស្រឡាញ់រាប់អានពីមនុស្សទូទៅ មានកេរ្តិ៍ឈ្មោះល្អ មានសេចក្តីក្លាហានក្នុ

ងទីប្រជុំ ព្រោះលោកពុំមានកំហុសអំពីរឿងអ្វីមួយ ។ ប្រជាប្រិយភាពបែបនេះ កើតឡើងដោយសារគុណធម៌របស់លោកអ្នកមានធម៌ក្នុងខ្លួន ។ អ្នកមានធម៌ក្នុងខ្លួនរមែងបានសុខកាយសប្បាយចិត្តក្នុងបច្ចុប្បន្ន ដោយលោកមិនមានទោសសត្រូវជាមួយអ្នកដទៃដែលធ្វើឲ្យអ្នកដទៃចងអាឃាតព្យាបាទលោកឡើយ ផ្ទុយទៅវិញធ្វើឲ្យអ្នកដទៃគោរពកោតក្រែង ជឿទុកចិត្ត ហើយកិច្ចការសំខាន់ៗរបស់សង្គម តែងតែពិគ្រោះជាមួយលោក ។ សេចក្តីសុខសន្តិភាពនិងវឌ្ឍនភាពនៃសង្គមមនុស្ស ត្រូវកើតឡើងពីមនុស្សម្នាក់ៗទៅ ហើយបើមនុស្សគ្រប់រូបមានធម៌ក្នុងខ្លួន វាធ្វើឲ្យសង្គមគ្រួសារ ធ្វើឲ្យប្រទេស និងធ្វើឲ្យពិភពលោកទាំងមូលបានសុខសន្តិភាពដែរ ។ ពាក្យថាមានធម៌ក្នុងខ្លួន តាមន័យរបស់ព្រះពុទ្ធសាសនា ត្រូវស្មើគ្នានឹងពាក្យដែលផ្លូវលោកគេប្រើសព្វថ្ងៃថា ជាអ្នកគោរពសិទ្ធិអ្នកដទៃនោះឯង ។ អ្នកមានសីលក្នុងខ្លួន ឈ្មោះថាមិនបៀតបៀនអ្នកដទៃ អ្នកធ្វើទានឈ្មោះថា ជួយសង្គ្រោះអ្នកដទៃ អ្នកចំរើនមេត្តាភាវនា ឈ្មោះថាធ្វើចិត្តឲ្យស្ងប់ កុំឲ្យគិតធ្វើអំពើបាបអ្នកដទៃ ។ ក្នុងមង្គលសូត្រពាក្យមួយឃ្លាថា អត្តសម្មាបណីធិច ប្រែថាការដឹកល់ខ្លួនដ៏ប្រពៃក្នុងបច្ចុប្បន្នជាមង្គលដ៏ឧត្តម ។ ពាក្យថាមង្គលប្រែថា សេចក្តីចំរើន គឺចំរើនដោយសេចក្តីសុខ ។ ដឹកល់ខ្លួនដោយប្រពៃ គឺដឹកល់ខ្លួនក្នុងទានសីលភាវនានេះឯង ។ មានធម៌ក្នុងខ្លួន គឺស្មើនឹងពាក្យថា មានទានសីលភាវនាក្នុងខ្លួនដូចគ្នាដែរ ។

ពិភពលោកសព្វថ្ងៃនេះ គេអប់រំមនុស្សឲ្យស្គាល់តម្លៃមនុស្ស អប់រំមនុស្សឲ្យគោរពសិទ្ធិមនុស្ស គឺអប់រំមនុស្សឲ្យគោរពច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ អ្នកមានធម៌ក្នុងខ្លួននៃពុទ្ធភាសិតខាងដើមនេះ ឈ្មោះថាគោរពសិទ្ធិអ្នកដទៃនេះឯង ។ ពាក្យថាមានធម៌ក្នុងខ្លួននេះ មានជំរៅជាងច្បាប់អាណាចក្រទៅទៀត គឺជាបុគ្គលស្ងប់ មិនប្រព្រឹត្តអំពើបៀតបៀនគ្រប់យ៉ាងដល់អ្នកដទៃ សូម្បីគិតថាបៀតបៀនតាមផ្លូវចិត្ត ក៏ហាមមិនឲ្យគិតទៅទៀត ។ មិនតែប៉ុណ្ណោះ សីលធម៌ព្រះពុទ្ធសាសនាមានកម្រិតខ្ពស់ណាស់ សូម្បីតែសត្វតិរច្ឆាន ក៏ព្រះពុទ្ធណែនាំកុំឲ្យបៀតបៀន កុំឲ្យសម្លាប់ដូចគ្នា ។ ដូច្នេះបើពិភពលោកនាំគ្នាសិក្សា នាំគ្នាប្រតិបត្តិតាមធម៌ព្រះពុទ្ធត្រង់ពុទ្ធភាសិត មនុស្សគ្រប់រូបត្រូវមានធម៌ក្នុងខ្លួននោះនឹងធ្វើឲ្យសង្គមតូចសង្គមធំ រហូតដល់សហគមន៍ពិភពលោកបានសុខសន្តិភាព ហើយអំពើហឹង្សាគ្រប់យ៉ាងរមែងពុំកើតឡើងឡើយ ។ ក៏ដូចគ្នានឹងសង្គ្រាមគ្រប់ប្រភេទក៏មិនកើតឡើងដែរ ព្រោះមនុស្សគ្រប់រូបមានធម៌ក្នុងខ្លួន ។ បានសេចក្តីថា បើបុគ្គលមួយរូបៗមានធម៌ក្នុងខ្លួន បានសុខខ្លួនឯងផង ធ្វើឲ្យសង្គមមនុស្សបានសុខផង ។ បើនិយាយដល់ជំរៅព្រះពុទ្ធសាសនា បើអ្នកមានធម៌ក្នុងខ្លួនដល់កម្រិតខ្ពស់ នឹងបានសំរេចព្រះនិព្វាន ជាការរំលត់ទុក្ខ ចេញផុតពីការកើតចាស់ឈឺស្លាប់ ដែលជាទុក្ខធំបំផុតក្នុងសង្សារវដ្ត ៚